ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 11-Feb-2015, 15:42
CMS/CFO: Sann Rada

## នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
## នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អវតក/អជសដ
ដាក់ទៅ : អង្គជំនុំជម្រះសាលាដំបូង
ថ្ងៃដាក់ : ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៥
ភាគីអ្នកដាក់ : សហព្រះរាជអាជ្ញាអន្តរជាតិ
ភាសាដើម : អង់គ្លេស

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ** ជាមួយឧបសម្ព័ន្ធសម្ងាត់បំផុត៣

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ការដាក់បន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នូវឯកសារមួយចំនួនពីសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា
លោក Nicholas KOUMJIAN

**ចម្លងជូន:**
សហព្រះរាជអាជ្ញាជាតិ
លោកស្រី ជា លាង
សហចៅក្រមស៊ើបអង្កេត
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Mark B. HARMON

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ចម្លងជូន:**
ជនជាប់ចោទ
នួន ជា
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN

មេធាវីប្រចាំការ:
លោកស្រី ទូច វល័ក្ស
លោក Calvin SAUNDERS

# I. ការដាក់បង្ហាញ

1. សហព្រះរាជអាជ្ញាអន្តរជាតិ (“សហព្រះរាជអាជ្ញា”) សូមដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនម្ភៃ[1] និងឯកសារពាក់ព័ន្ធចំនួនបី[2] ដែលបានទទួលយករួចហើយនៅក្នុងសំណុំរឿង០០៤ ដែលពាក់ព័ន្ធទៅនឹងសវនាការក្នុងសំណុំរឿង០០២/០២។ ខណៈដែលកំណត់ហេតុទាំងអស់សុទ្ធតែពាក់ព័ន្ធនឹងសវនាការនៃសំណុំរឿង០០២/០២ ក៏មានឯកសារខ្លះស្ថិតនៅក្រោមឯកសារពីរប្រភេទ (“ប្រភេទរបស់មេធាវីការពារក្តី”) ដែលមេធាវីការពារក្តី នួន ជា បានកំណត់អត្តសញ្ញាណថា បើតាមទស្សនៈរបស់ខ្លួន ជាប្រភេទ “ដោះបន្ទុកដ៏មានសក្តានុពល” សម្រាប់បរិបទនៃបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ផងដែរ[3]។ ឯកសារទាំងអស់នេះសុទ្ធតែបានកំណត់អត្តសញ្ញាណនៅក្នុង **ឧបសម្ព័ន្ធ ឆ** សម្ងាត់បំផុត។

2. សហព្រះរាជអាជ្ញាសូមលើកយោងឯកសាររបស់ខ្លួនដែលបានដាក់គឺឯកសារលេខ E319[4] ជូនអង្គជំនុំជម្រះ ទាក់ទងនឹងប្រវត្តិនីតិវិធីពីមុនរបស់សហព្រះរាជអាជ្ញា នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីដាក់បង្ហាញឯកសារ។ ប្រវត្តិនីតិវិធីថ្មីបំផុតគឺនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាបាន

---

[1] កំណត់ហេតុចំនួនបី ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំង២០ គឺជាកំណត់ហេតុត្រឹមត្រូវ ចំណែកកំណត់ហេតុមួយក៏បានដាក់បង្ហាញក្នុងទម្រង់កោសលុប ស្របតាមដីកាសម្រេចរបស់ សចសអ។ សំណុំរឿង០០៤ - **D193/8** សេចក្តីសម្រេចមួយផ្នែកលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសវនាការនៃសំណុំរឿង០០២/០២ និងបណ្តឹងសាទុក្ខសំណុំរឿង០០២/០១, ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ (“សេចក្តីសម្រេចចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥”), កថាខណ្ឌ១៤។ សំណុំរឿង០០៤ - **D193/8.1** ឧបសម្ព័ន្ធ ក នៃសេចក្តីសម្រេចចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥។ សំណុំរឿង០០៤ - **D193/10** វិសោធនកម្មនៃសេចក្តីសម្រេចស្តីពីការដាក់បង្ហាញឯកសារ D193/4, D193/6, និង D193/8, ៣០ មករា ២០១៥ (“សេចក្តីសម្រេចវិសោធនកម្ម”)។

[2] ឯកសារដែលពាក់ព័ន្ធទាំងបី ត្រូវបានស្នើឲ្យកែតម្រូវលើកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនបី។ សំណុំរឿង០០៤ - **D193/8.1** ឧបសម្ព័ន្ធ ក នៃសេចក្តីសម្រេចចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥។

[3] **F2/4** សំណើលើកទីបី សុំឱ្យធ្វើការពិចារណា និងទទួលយកភស្តុតាងបន្ថែម ទាក់ទងបណ្តឹងសាទុក្ខប្រឆាំងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១, ២៥ វិច្ឆិកា ២០១៤, កថាខណ្ឌ៣៣។ ខណៈដែលសហព្រះរាជអាជ្ញាមិនយល់ស្របថា ប្រភេទឯកសារដែលបានកំណត់ដោយមេធាវីការពារក្តី នួន ជា ជាភស្តុតាងដោះបន្ទុកពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ សហព្រះរាជអាជ្ញាបានស្នើឱ្យ សចសអ ផ្តល់អាទិភាពចំពោះការពិចារណាក្នុងការដាក់បង្ហាញឯកសារទាំងនេះដើម្បីឱ្យមេធាវីការពារក្តី នួន ជា មានឱកាសបានពិនិត្យមើលឯកសារទាំងនោះសម្រាប់គោលបំណងនៃបណ្តឹងសាទុក្ខរបស់ខ្លួន។

[4] **E319** ការដាក់បង្ហាញកំណត់ហេតុនៃសំណុំរឿង០០៤ របស់សហព្រះរាជអាជ្ញាអន្តរជាតិ, ១៧ តុលា ២០១៤, កថាខណ្ឌ២-៤។

ដាក់សំណើមួយសុំឲ្យបង្ហាញឯកសារបន្ថែមពាក់ព័ន្ធនឹងប្រធានបទខុសៗគ្នា នៃសវនាការក្នុងសំណុំរឿង០០២/០២ (រួមទាំងឯកសារស្ថិតក្នុងប្រភេទរបស់មេធាវីការពារក្តីផងដែរ)[5]។ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ(សចសអ) បានចេញសេចក្តីសម្រេចមួយផ្អែកលើសំណើចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤ ដោយបានផ្តល់ការអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាដាក់បង្ហាញឯកសារដូចបានកំណត់អត្តសញ្ញាណក្នុង **ឧបសម្ព័ន្ធ ឆ**[6]។ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ សចសអ បានចេញសេចក្តីសម្រេចមួយដោយបានកែតម្រូវកំហុសឆ្គងក្នុងសេចក្តីសម្រេច ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ និងបានផ្តល់ការអនុញ្ញាតឲ្យសហព្រះរាជអាជ្ញា ដាក់បង្ហាញជូនមេធាវីប្រចាំការរបស់ ខៀវ សំផន បន្ថែមទៅលើមេធាវីការពារក្តីជនជាប់ចោទទាំងពីរ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី[7]។

3. អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា កាតព្វកិច្ចដើម្បីបង្ហាញសម្ភារៈពាក់ព័ន្ធ ទោះជាដាក់បន្ទុក ឬដោះបន្ទុកក្តី គឺជាកាតព្វកិច្ចមួយដែលអង្គជំនុំជម្រះសាលាដំបូងជាប់ជំពាក់ ដូចគ្នានឹងជនជាប់ចោទដែរ ដោយហេតុថា "វាជាប្រយោជន៍ដែលនាំដល់ការស្វែងរកការពិត បើអង្គជំនុំជម្រះមានសិទ្ធិចូលពិនិត្យមើលឯកសារទាំងនេះ"[8]។ ជាងនេះទៀត អង្គជំនុំជម្រះនេះធ្លាប់បានសម្រេចពីមុនថា "វិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង ដាក់កាតព្វកិច្ចជាបន្តបន្ទាប់ទៅលើសហព្រះរាជអាជ្ញា ក្នុងការបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង នូវសម្ភារៈណាមួយដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួន ដែលអាចជានត្ថិភាពនៃពិរុទ្ធ ឬសម្រាលពិរុទ្ធរបស់ជនជាប់ចោទ ឬអាចមានឥទ្ធិពលទៅលើភាពជឿ

[5] សំណុំរឿង០០៤ - **D193/7** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសវនាការនៃសំណុំរឿង០០២/០២ និងបណ្តឹងសាទុក្ខនៃសំណុំរឿង០០២/០១, ១៥ ធ្នូ ២០១៤ ("សំណើចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤")។

[6] សេចក្តីសម្រេចចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ សេចក្តីសម្រេចវិសោធនកម្ម, កថាខណ្ឌ៥-៦។ សេចក្តីសម្រេចចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ក៏បានផ្តល់ការអនុញ្ញាតឲ្យដាក់បង្ហាញកំណត់ហេតុបួនផ្សេងទៀតផងដែរ ដែលការដាក់បង្ហាញនេះ បានទទួលការអនុញ្ញាតពីមុនរួចម្តងហើយ តាមរយៈសេចក្តីសម្រេចដាច់ដោយឡែកមួយ។ ដោយសារកំណត់ហេតុស្តាប់ចម្លើយទាំងបួននោះត្រូវបានដាក់បង្ហាញពីមុនរួចហើយ ដូច្នេះកំណត់ហេតុទាំងនោះមិនត្រូវបានដាក់បង្ហាញទៀតទេនៅពេលនេះ។

[7] សេចក្តីសម្រេចវិសោធនកម្ម។

[8] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២", ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២។

ដាក់បាននៃភស្តុតាង"[9]។ អង្គជំនុំជម្រះសាលាដំបូងបានណែនាំឲ្យសហព្រះរាជអាជ្ញាដំបូងត្រូវដាក់សំណើសុំបង្ហាញរបស់ខ្លួនទៅអង្គជំនុំជម្រះដោយប្តឹងពីភស្តុតាងដែលខ្លួនចង់ដាក់បង្ហាញ ហើយបន្ទាប់មកទើបដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូង សុំឲ្យទទួលយកឯកសារនោះ ដែលឯកសារនោះបានយល់ព្រមរួចហើយសម្រាប់ការដាក់បង្ហាញ[10]។

4. អង្គជំនុំជម្រះសាលាដំបូងពីមុនធ្លាប់បានបង្គាប់ថា គ្រប់ការដាក់បង្ហាញឯកសារទាំងអស់ ពីសំណុំរឿង០០៣ និង០០៤ ទៅក្នុងសំណុំរឿង០០២ គម្បីដាក់ និងជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងជាបណ្តោះអាសន្នដោយឈរលើមូលដ្ឋានសម្ងាត់បំផុត និងថាបន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការកំណត់ចំពោះឯកសារនោះថាតើ គម្បីដាក់ចំណាត់ថ្នាក់ឡើងវិញថា សម្ងាត់ ឬក៏អត់[11]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង អំពីកំណត់ហេតុដែលមាននៅក្នុង **ឧបសម្ព័ន្ធ ឆ** ដោយឈរលើមូលដ្ឋានសម្ងាត់បំផុត។ សចសអ ក៏បានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញា ដាក់បង្ហាញសេចក្តីសម្រេចចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ជូនតែអង្គជំនុំជម្រះសាលាដំបូងមួយគត់[12]។ សេចក្តីសម្រេចចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ និងឧបសម្ព័ន្ធ ក ដែលបានដាក់ភ្ជាប់ទៅជាមួយនឹងសេចក្តីសម្រេចនេះ ក៏បានភ្ជាប់ទៅជាមួយ **ឧបសម្ព័ន្ធ ១** និង **១ក** សម្ងាត់បំផុត[13] ជាបន្តបន្ទាប់។

5. ការអនុញ្ញាតរបស់ សចសអ ដើម្បីដាក់បង្ហាញឯកសារ មានការដាក់កម្រិត និងកាតព្វកិច្ចខ្លះៗដែរ ហើយសំណើរបស់ សចសអ គឺអង្គជំនុំជម្រះសាលាដំបូង ជាអ្នកធានាឲ្យប្រាកដចំពោះការអនុវត្ត

---

[9] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២", ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២, ត្រង់ទំព័រទី១។

[10] **E127/7/1** ព័ត៌មានពាក់ព័ន្ធនឹងចម្លើយសាក្សីសំណុំរឿង០០៣ និងសំណុំរឿង០០៤ ដែលអាចពាក់ព័ន្ធនឹងសំណុំរឿង០០២, ១៦ សីហា ២០១៣, កថាខណ្ឌ២។

[11] **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២", ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២, ត្រង់ទំព័រទី១។

[12] សេចក្តីសម្រេចចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥, កថាខណ្ឌ១៩។

[13] សេចក្តីសម្រេចវិសោធនកម្ម ត្រូវបានចែកជូនអង្គជំនុំជម្រះសាលាដំបូង (ព្រមទាំងសហព្រះរាជអាជ្ញា) តាមរយៈការដាក់ឯកសាររបស់ សចសអ។

តាមសេចក្តីសម្រេចអំពីការដាក់បង្ហាញឯកសារ ដោយគ្រប់ភាគីទាំងអស់[14]។ ការអនុញ្ញាតស្តីពីការដាក់បង្ហាញឯកសាររបស់ សចសអ ដាក់កម្រិត និងកាតព្វកិច្ចមួយចំនួនដូចខាងក្រោម៖

ក. ត្រូវចាត់ទុកជាឯកសារសម្ងាត់[15]។

ខ. មិនត្រូវផ្តល់សំណៅចម្លងអេឡិចត្រូនិចទៅភាគីណាមួយឡើយ ក្រៅពីអង្គជំនុំជម្រះសាលាដំបូង[16]។

គ. ឯកសារដែលត្រូវផ្តល់ជូនមេធាវីការពារក្តីជនជាប់ចោទទាំងពីរ មេធាវីប្រចាំការរបស់ ខៀវ សំផន និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវមានសញ្ញាសម្គាល់ និងមានលេខនៅលើសំណៅចម្លង[17]។

ឃ. កសពជាអ្នកថែរក្សាកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលមានសញ្ញាសម្គាល់ និងលេខនៅលើសំណៅចម្លងនោះ រួមទាំងភាគីដែលទទួលបានសំណៅចម្លងនិមួយៗតាមរយៈការដាក់បង្ហាញនោះ តាមរបៀបមួយដែលអាចឲ្យគេពិនិត្យមើលបាន ក្នុងករណីចាំបាច់[18]។

ង. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់បង្ហាញសម្ភារៈទាំងឡាយជូនតែសមាជិកនៃក្រុមរបស់ពួកគាត់ប៉ុណ្ណោះ ដោយត្រូវគោរពតាមវិធាន២២(៥) និងវិធាន១២(៤)*ស្ទួនពីរ* ជាបន្តបន្ទាប់[19]។

ច. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនអនុញ្ញាតឲ្យផលិតឡើងវិញ ថតចម្លង ស្កេន ឬបង្កើតឲ្យមានចំណៅជាពីរច្បាប់ពីច្បាប់

[14] សេចក្តីសម្រេចចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥, កថាខណ្ឌ១៤, ១៥ & ១៨។ សេចក្តីសម្រេចវិសោធនកម្ម, កថាខណ្ឌ៨។
[15] សេចក្តីសម្រេចវិសោធនកម្ម, កថាខណ្ឌ៨(ក)។
[16] សេចក្តីសម្រេចវិសោធនកម្ម, កថាខណ្ឌ៨(ខ)។
[17] សេចក្តីសម្រេចវិសោធនកម្ម, កថាខណ្ឌ៨(គ)។
[18] សេចក្តីសម្រេចវិសោធនកម្ម, កថាខណ្ឌ៨(ឃ)។
[19] សេចក្តីសម្រេចវិសោធនកម្ម, កថាខណ្ឌ៨(ង)។

ដើម ទោះបីជាតាមរបៀបណាក៏ដោយ ដែលនាំឲ្យសមាជិកនៃក្រុមរបស់ខ្លួននិមួយៗដែល ទទួលបានការណែនាំ ឬអនុញ្ញាតឲ្យចូលពិនិត្យមើលសម្ភារៈសម្ងាត់ យកសម្ភារៈទាំងនោះ ទៅប្រើប្រាស់ ក្រៅពីការប្រើប្រាស់ផ្ទៃក្នុងរបស់ខ្លួនឡើយ[20]។

ឆ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវថែរក្សាកំណត់ហេតុជាលាយលក្ខណ៍អក្សរ នៃការធ្វើចរាចរឯកសារជាសំណៅចម្លង ដែលបានផ្តល់ទៅឲ្យពួកគាត់ តាមរបៀបមួយដែលអាចឲ្យគេចូលពិនិត្យមើលបាន បើសិន ជាមានតម្រូវការ[21]។

ជ. បើសិនជាសម្ភារៈនោះ ត្រូវបានទទួលយកជាភ័ស្តុតាងក្នុងសំណុំរឿង០០២/០២ សម្ភារៈ នោះគួរតែគប្បីត្រូវបានចាត់ទុកថា សម្ងាត់[22]។

ឈ. គ្មានសម្ភារៈណាមួយដែលបានដាក់បញ្ចូលក្នុងការដាក់បង្ហាញឯកសារនេះ ត្រូវបានផ្សព្វ ផ្សាយឲ្យហួសពីបុគ្គលដូចបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងការដាក់បង្ហាញនោះឡើយ[23]។

ញ. គ្មានសម្ភារៈណាមួយដែលបានដាក់បញ្ចូលក្នុងការដាក់បង្ហាញឯកសារនេះ ត្រូវបានផ្សព្វ ផ្សាយជាសាធារណៈឡើយ ទោះក្នុងទម្រង់ ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានណាមួយ ក៏ដោយ ហើយគោលបំណងនៃការដាក់កម្រិតនេះ ពាក្យថា "សាធារណៈ" មានន័យថា គ្រប់មនុស្ស រដ្ឋាភិបាល អង្គការ ស្ថាប័ន កូនក្តី សមាគម និងក្រុមទាំងអស់ ក្រៅពី ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង បុគ្គលិកផ្នែកគ្រប់គ្រងតុលាការ សហព្រះរាជអាជ្ញា និងតំណាងរបស់ខ្លួន ជនជាប់ចោទ និងបុគ្គលិកដូចបានកំណត់ជាផ្លូវការក្នុងវិធាន២២(៥) និងវិធាន១២(៤)*ស្ទួនពីរ* ដែលបានអនុញ្ញាតដោយក្រុមមេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចចូលពិនិត្យមើលសម្ភារៈសម្ងាត់ នោះបានឡើយ។ ពាក្យថា "សាធារណៈ" ក៏រាប់បញ្ចូលផងដែរ ដោយគ្មានកម្រិតនូវ

[20] សេចក្តីសម្រេចវិសោធនកម្ម, កថាខណ្ឌ៨(ច)។

[21] សេចក្តីសម្រេចវិសោធនកម្ម, កថាខណ្ឌ៨(ឆ)។

[22] សេចក្តីសម្រេចវិសោធនកម្ម, កថាខណ្ឌ៨(ជ)។

[23] សេចក្តីសម្រេចវិសោធនកម្ម, កថាខណ្ឌ៨(ឈ)។

សមាជិកគ្រួសារ មិត្តភ័ក្តិរបស់ជនជាប់ចោទ និងអ្នកដែលជនជាប់ចោទធ្លាប់សេពគប់ជនសង្ស័យ មេធាវីការពារក្តី និងសមាជិកនៃបុគ្គលិករបស់ពួកគាត់រៀងៗខ្លួននៅក្នុងសំណុំរឿង ឬដំណើរការនីតិវិធីផ្សេងៗទៀតនៅចំពោះមុខ អ.វ.ត.ក ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មាន[24]។

ង. បើសមាជិកណាម្នាក់នៃភាគី ឬអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០២ ដឹងអំពីការផ្តល់ជូនសំណៅសម្ភារៈឯកសារណាមួយដែលគ្មានការអនុញ្ញាត សមាជិករូបនោះត្រូវចាត់គ្រប់វិធានការទាំងអស់ជាបន្ទាន់ ដើម្បីរក្សាការពារ និងយកត្រឡប់មកវិញនូវសំណៅសម្ភារៈឯកសារនោះ ជូន សចអ[25]។

ច. បើសមាជិកណាម្នាក់នៃភាគី ឬអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០២ ដឹងអំពីការរំលោភបំពានលើលក្ខខណ្ឌ ឬការដាក់កម្រិតទាំងនេះ សមាជិករូបនោះត្រូវរាយការណ៍ជូន សចអ អំពីការរំលោភបំពាននោះ[26]; និង

ឆ. ការដាក់កម្រិតទាំងនេះ នឹងនៅជាធរមានរហូតដល់មានសេចក្តីសម្រេចច្បាស់លាស់ផ្សេងពីនេះ ដោយ សចស ឬរហូតដល់ពេលបិទកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤[27]។

6. ដើម្បីអនុវត្តតាមការដាក់កម្រិតទាំងនេះ សហព្រះរាជអាជ្ញានឹងធ្វើយ៉ាងណាឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តី នួន ជា មេធាវីការពារក្តី ខៀវ សំផន និងមេធាវីប្រចាំការរបស់ ខៀវ សំផន នូវឯកសារមួយដែលបានដាក់សញ្ញាសម្គាល់ និងលេខលើសំណៅចម្លងនៃឯកសារនិមួយៗ ដល់គ្រប់ភាគីទាំងអស់ឲ្យបានឆាប់តាមដែលអាចធ្វើបាន។

---

[24] សេចក្តីសម្រេចវិសោធនកម្ម, កថាខណ្ឌ៨(ញ)-៩។

[25] សេចក្តីសម្រេចវិសោធនកម្ម, កថាខណ្ឌ៨(ដ)។

[26] សេចក្តីសម្រេចវិសោធនកម្ម, កថាខណ្ឌ៨(១)។

[27] សេចក្តីសម្រេចចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥, កថាខណ្ឌ១៧។

## II. ដំណោះស្រាយដែលស្នើឡើង

7. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ទទួលយក និងដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២ នូវកំណត់ហេតុស្តាប់ចម្លើយសាក្សីដូចបានកំណត់អត្តសញ្ញាណក្នុង **ឧបសម្ព័ន្ធ ឆ** ស្របទៅតាមការអនុញ្ញាតឲ្យដាក់បង្ហាញឯកសាររបស់ សចសអ ដូចបានភ្ជាប់ទៅជាមួយស្រាប់ក្នុង **ឧបសម្ព័ន្ធ ១** និង **១ក** ដែលបានកែសម្រួលតាមរយៈសេចក្តីសម្រេចវិសោធនកម្ម៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៥ | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |